# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣២ សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសេចក្តីត្រូវការចាំបាច់របស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងនាវាសញ្ជាតិកម្ពុជា

## សម្រេច

**ប្រការ១ :** បង្កើតគណៈកម្មាធិការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **សេង លឹមនៅ** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- | ឯកឧត្តម **ញាណ ឡេង** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- | ឯកឧត្តម **ឡេង ធនយុទ្ធា** | អគ្គនាយកដឹកជញ្ជូននៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៤- | បណ្ឌិត **ជា វ៉ាន់ដេត** | ជំនួយការឯកឧត្តមទេសរដ្ឋមន្ត្រី សុខ អាន | សមាជិក |
| ៥- | លោក **ឃុយ ហៀង** | អនុប្រធាននាយកដ្ឋានគមនាគមន៍ និងប្រៃសណីយ៍ | សមាជិក |

**ប្រការ២ :** គណៈកម្មាធិការនេះ មានភារកិច្ចគ្រប់គ្រងការចុះបញ្ជីនាវាសមុទ្រ និងធ្វើឱ្យប្រសើរនូវស្ថានភាពនាវាដាក់ទង់ជាតិកម្ពុជា ដើម្បីស្តារកិត្តិយសប្រទេសជាតិឡើងវិញ។

**ប្រការ៣ :** គណៈកម្មាធិការនេះ ត្រូវអនុវត្តតាមស្មារតីនៃកិច្ចព្រមព្រៀង ដែលបានចុះហត្ថលេខារវាងតំណាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនចុះបញ្ជីនាវាសមុទ្រអន្តរជាតិកម្ពុជា។ គណៈកម្មាធិការមានភារកិច្ចតាមដាន និងត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀង របស់ក្រុមហ៊ុនចុះបញ្ជីនាវាសមុទ្រអន្តរជាតិកម្ពុជា។

**ប្រការ៤** : គណៈកម្មាធិការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី លើលិខិតផ្លូវការរបស់ខ្លួន។

**ប្រការ៥** : រាល់បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឯកឧត្តម អស់លោក ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចំលងជូន:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ